# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាខេត្តតាកែវ**

លេខ ២២៣ ស.ជ.ណ

តាកែវ ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៤

យោងតាមប្រកាសលេខ ៥៤៨ សហវ.ប្រក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការប្រមូលពន្ធលើមធ្យាបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៤។

***សាលាខេត្តតាកែវ*** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឯកឧត្ដម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងអស់ នៅក្នុងខេត្តតាកែវ សូមមេត្តាជ្រាបថា ៖ ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៤ ត្រូវបាន អនុវត្តប្រមូលចាប់ពី **ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ តទៅ នឹង ត្រូវបញ្ចប់នៅ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។**

ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៤ នៅសាខាពន្ធដារខេត្ត ឬនៅធនាគារកាណាឌីយ៉ា ក.អ កម្ពុជា ប្រចាំខេត្តតាកែវ ឬនៅធនាគារអេស៊ីលីដា ភី អិល ស៊ី គ្រប់ស្រុក ដោយត្រូវបំពេញលិខិតប្រកាសបង់ពន្ធចំនួន**០២សន្លឹក** តាមទម្រង់ដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ ។ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទត្រូវភ្ជាប់មកជាមួយនូវ **ប័ណ្ណសម្គាល់យានយន្ត ឬបង្កាន់ដៃបង់ពន្ធនាំចូល ឬវិញ្ញាបនប័ត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត និងអត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួនរបស់ម្ចាស់មធ្យោបាយដឹកជញ្ជូន ។ ដោយឡែកទោចក្រយានយន្ត និងត្រីចក្រយានយន្តដែលបំពាក់ដោយម៉ាស៊ីនម៉ូតូ មិនមានកាតព្វកិច្ចបំពេញលិខិតប្រកាស និងមិនចាំបាច់ភ្ជាប់មកជាមួយនូវឯកសារផ្សេងៗទេ។**

ក្រោយពេលបង់ពន្ធរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ត្រូវទទួលបានលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធមួយសន្លឹក បង្កាន់ដៃបង់ពន្ធមួយសន្លឹក និងលតាបត្រសម្រាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះមួយសន្លឹក ។ លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ លិខិតនេះត្រូវថែរក្សាទុកជាប់នឹងយានយន្តសម្រាប់បង្ហាញមន្ត្រីមានសមត្ថកិច្ច និងជាឯកសារសម្រាប់ប្រកាសបង់ពន្ធនៅឆ្នាំបន្ទាប់។

ចាប់ពីថ្ងៃទី០១ **ខែមករា ឆ្នាំ២០១៥** តទៅ អង្គភាពពន្ធដារត្រូវធ្វើការត្រួតពិនិត្យការបង់ពន្ធ និងផាកពិន័យចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះទាំងឡាយណា ដែលមិនទាន់បានប្រកាសបង់ពន្ធ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងអស់ សូមមេត្តាអញ្ជើញទៅបង់ពន្ធ ឲ្យបានទាន់ពេលវេលាតាមកាលបរិច្ឆេទកំណត់ខាងលើនេះ ។

**សាលាខេត្តតាកែវ** សង្ឃឹម និងជឿជាក់ថា ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងអស់ ពិតជាបានយល់ និងអញ្ជើញមកបំពេញកាតព្វកិច្ចប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០១៤ បានគ្រប់ៗគ្នា កុំបីអាក់ខាន។៚

**អភិបាលខេត្ត**

L. Vamac

**ឡាយ វណ្ណៈ**

**<u>ចម្លងជូន</u>**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរ-អង្គភាពជុំវិញខេត្ត
- គ្រប់សាលាស្រុក-ក្រុង
  "ដើម្បីជួយផ្សព្វផ្សាយ និងសហការអនុវត្ត"
- ស្ថានីយវិទ្យុ៩២,៥MH₂ "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ